ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ:......០៣៤......សណន.សក.ជជគ

# សេចក្តីណែនាំ
## ស្តីពី
## វិធានការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ រលកទី២ ដល់ការដឹកជញ្ជូនអ្នកដំណើរតាមរថយន្ត ក្នុងព្រះរាជាណាចក្រកម្ពុជា

យោងតាមសេចក្តីប្រកាសរបស់ក្រសួងសុខាភិបាល បច្ចុប្បន្ននេះជំងឺកូវីដ-១៩ នៅតែជាក្តីព្រួយបារម្ភបំផុតរបស់ពិភពលោក និងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ខ្ពស់នៅឡើយ។ ជាមួយគ្នានេះ ក្រសួងសាធារណការ និងដឹកជញ្ជូនបានសង្កេតឃើញថា មានបងប្អូនប្រជាពលរដ្ឋដែលប្រើប្រាស់មធ្យោបាយដឹកជញ្ជូនភាគច្រើន នៅមានការធ្វេសប្រហែសក្នុងការការពារខ្លួនតាមវិធានការរបស់ក្រសួងសុខាភិបាល។ ជាថ្មីម្តងទៀត ក្រសួងសាធារណការ និងដឹកជញ្ជូនសូមធ្វើការណែនាំដល់ម្ចាស់ក្រុមហ៊ុន ម្ចាស់យានយន្តធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ អ្នកបើកបររថយន្ត និងអ្នកបម្រើភ្ញៀវលើរថយន្តដឹកអ្នកដំណើរ ព្រមទាំងបងប្អូនប្រជាពលរដ្ឋដែលជាអ្នកដំណើរទាំងអស់ សូមបន្តការយកចិត្តទុកដាក់អនុវត្តវិធានការទប់ស្កាត់ការរីករាលដាល ជំងឺកូវីដ-១៩ រលកទី២ ដូចខាងក្រោម៖

១. រក្សាគម្លាតសុវត្ថិភាព និងសម្អាតកន្លែងផ្តល់សេវាដល់អតិថិជនឱ្យបានស្អាតជានិច្ច ជាពិសេសនៅកន្លែងលក់សំបុត្រ កន្លែងរង់ចាំ កន្លែងទទួលទានអាហារ បង្គន់អនាម័យ ។ល។
២. ត្រួតពិនិត្យសុខភាពអ្នកបើកបរ និងបុគ្គលិកបម្រើសេវាជាប្រចាំ និងគួរឱ្យពួកគាត់ពាក់ម៉ាស់ក្នុងពេលបំពេញការងារ។ បើមានការសង្ស័យលើសុខភាពរបស់ពួកគាត់ ត្រូវឱ្យពួកគាត់ឈប់សម្រាកជាបណ្តោះអាសន្ន ដើម្បីតាមដានសុខភាព។
៣. វាស់កំដៅអ្នកដំណើរ និងប្រើទឹកអាល់កុលសម្រាប់លាងដៃមុននឹងអនុញ្ញាតឱ្យឡើងលើរថយន្ត។
៤. ប្រសិនបើពិនិត្យឃើញអ្នកដំណើរមានអាការៈដូចជា៖ ក្តៅខ្លួនលើសពី **៣៧,២ អង្សាសេ** មានក្អក ឬឈឺបំពង់ក ឬមានបញ្ហាក្នុងការដកដង្ហើម មិនត្រូវអនុញ្ញាតឱ្យឡើងជិះរថយន្តឡើយ និងត្រូវណែនាំឱ្យគាត់ទៅមណ្ឌលសុខភាពដែលនៅជិតបំផុតជាបន្ទាន់ ឬទូរស័ព្ទទៅបណ្តាញទំនាក់ទំនងទាន់ហេតុការណ៍ លេខ**១១៥** របស់ក្រសួងសុខាភិបាល។
៥. ម្ចាស់ ឬអ្នកគ្រប់គ្រងរថយន្តដឹកជញ្ជូនអ្នកដំណើរ ត្រូវប្រើប្រាស់អាល់កុល ឬសារធាតុសម្លាប់មេរោគ ដើម្បីជូតសំអាតរាល់វត្ថុទាំងឡាយនៃរថយន្ត ដែលអ្នកធ្វើដំណើរតែងប៉ះពាល់ជាប្រចាំ ដូចជា៖ របារតោងភ្ជាក់ដៃ កៅអី ។ល។ ឱ្យបានញឹកញាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន។
៦. ចូលរួមផ្សព្វផ្សាយដល់អ្នកដំណើរទាំងអស់ ឱ្យប្រកាន់យកនូវវិធានអនាម័យស្អាតជានិច្ច ដោយឧស្សាហ៍លាងដៃក្រោយចាប់កាន់របស់ផ្សេងៗ មុននិងក្រោយបរិភោគអាហារ និងមានម៉ាស់ ឬក្រម៉ាការពារពេលក្អក ឬកណ្តាស់ក្នុងពេលធ្វើដំណើរ។

ក្រសួងសាធារណការនិងដឹកជញ្ជូនសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ក្រុមហ៊ុន ម្ចាស់រថយន្តដឹកជញ្ជូនអ្នកដំណើរ អ្នកបើកបរ និងអ្នកបម្រើភ្ញៀវលើរថយន្តដឹកអ្នកដំណើរ ព្រមទាំងប្រជាពលរដ្ឋដែលធ្វើដំណើរតាមរថយន្តដឹកជញ្ជូនអ្នកដំណើរទាំងអស់ នឹងចូលរួមអនុវត្តតាមសេចក្តីណែនាំខាងលើនេះដោយយកចិត្តទុកដាក់ខ្ពស់បំផុត។

ថ្ងៃ.................ខែ.........ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី....១៥....ខែ..តុលា...ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**